ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
ទីក្រុងស្អាត ត្រូវផ្ដើមចេញពីយើងទាំងអស់គ្នា

គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត
លេខៈ ០២៨ គជវស. តទស

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០១៥

**សេចក្ដីជូនដំណឹង**
**ស្ដីពី**
**ការត្រៀមចូលរួមចលនាប្រឡងប្រណាំង "ស្តង់ដាទីក្រុងទេសចរណ៍ស្អាតអាស៊ាន"**
(ASEAN Clean Tourist City Standard)

**គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត/ក្រសួងទេសចរណ៍** មានកិត្តិយសសូមជម្រាបជូន **ឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត** និងអភិបាលក្រុងទូទាំងព្រះរាជាណាចក្រកម្ពុជា មេត្តាជ្រាបថា **ស្តង់ដាទីក្រុងទេសចរណ៍ស្អាតអាស៊ាន** (ASEAN Clean Tourist City Standard) ដែលមានប្រទេសកម្ពុជាជាប្រទេសនាំមុខក្នុងការរៀបចំនៅក្នុងថ្នាក់តំបន់ ត្រូវបានអនុម័តជាផ្លូវការដោយរដ្ឋមន្ត្រីទេសចរណ៍អាស៊ាននាឱកាសវេទិកាទេសចរណ៍អាស៊ាន (ATF) ២០១៥ នៅទីក្រុងណៃពិដោ ប្រទេសមីយ៉ាន់ម៉ា។

នៅក្នុងក្របខ័ណ្ឌនៃការអនុវត្តស្តង់ដានេះតម្រូវអោយប្រទេសជាសមាជិកអាស៊ានទាំងអស់ ជ្រើសរើសនូវទីក្រុងទេសចរណ៍លេចធ្លោរបស់ខ្លួន ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានឡាបិលទីក្រុងទេសចរណ៍ស្អាតរបស់អាស៊ាន។ អាស្រ័យហេតុនេះ **គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត/ក្រសួងទេសចរណ៍** សូមជម្រាបជូនដំណឹងដល់**ឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត** និងអភិបាលក្រុងទូទាំងព្រះរាជាណាចក្រកម្ពុជា មេត្តាត្រៀមខ្លួនចូលរួមអនុវត្ត**ស្តង់ដាទីក្រុងទេសចរណ៍ស្អាតអាស៊ាន**នេះឲ្យបានផុសផុល ដើម្បីជាកិត្តិយសជាតិដ៏ឧត្តុង្គឧត្តមថ្មីមួយទៀត បន្ទាប់ពីការទទួលបានជោគជ័យក្នុងការអនុវត្តចលនាប្រឡងប្រណាំង**ទីក្រុងស្អាត** នៅកម្រិតថ្នាក់ជាតិនៅកម្ពុជា។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់អគ្គលេខាធិការដ្ឋាននៃ**គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត/ក្រសួងទេសចរណ៍** រៀងរាល់ម៉ោងធ្វើការ ឬតាមរយៈទូរស័ព្ទលេខ ០៩៦ ៣៥ ៧៨៦ ៣២ ឬអ៊ីម៉ែល nechamnap007@gmail.com។

ទទួលបានសេចក្ដីជូនដំណឹងនេះ សូម **ឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត** និងអភិបាលក្រុងទូទាំងព្រះរាជាណាចក្រកម្ពុជា ជ្រាបជាព័ត៌មាន និងត្រៀមរៀបចំទីក្រុងនៅតាមរាជធានី-ខេត្តរបស់ខ្លួនឲ្យក្លាយជាទីក្រុងទេសចរណ៍ដ៏លេចធ្លោដើម្បីចូលរួមចលនាប្រឡងប្រណាំងនេះ ឲ្យបានផុសផុល។

**គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត**
**ប្រធាន**

**ថោង ខុន**
**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**<u>ចម្លងជូនៈ</u>**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- សមាជិក សមាជិកា នៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត

*"ដើម្បីជូនជ្រាប"*
- សាលារាជធានី-ខេត្តទាំង២៥
- ប្រធានក្រុមការងារវាយតម្លៃទីក្រុងស្អាតរាជធានី-ខេត្ត
- អភិបាលក្រុង-ខណ្ឌទាំងអស់
- មន្ទីរទេសចរណ៍រាជធានី-ខេត្ត

**"ដើម្បីអនុវត្ត"**
- ឯកសារ-កាលប្បវត្តិ

ដីឡូត៍លេខ ៣A ផ្លូវលេខ ១៦៩ សង្កាត់វាលវង់ ខណ្ឌ ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ១៦ ៧៣៨ ៤០៣ ទូរសារ: +៨៥៥ ២៣ ៨៨៥ ០១៨